ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ១២៦៨ ចុះថ្ងៃទី១៧.១២.២០១៥។
សំណុំរឿងជំនុំជម្រះលេខ ២១៣ ចុះថ្ងៃ១០.០៣.២០១៦។
សាលក្រមលេខ ៨៨ "ឈ"
ចុះថ្ងៃទី២២/០៦/២០១៦។

## អានាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តសៀមរាប។
កាលបរិច្ឆេទនៃសវនាការ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦។
កាលបរិច្ឆេទនៃការប្រកាសសាលក្រមថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៦។

### ចៅក្រមជំនុំជម្រះ

លោក [redacted]ាន:ជាចៅក្រមជំនុំជម្រះ។

### តំណាងអយ្យការ

លោក [redacted] បាន:ជាព្រះរាជអាជ្ញារង។

### ក្រឡាបញ្ជីសវនាការ

លោក [redacted] បាន:ជាក្រឡាបញ្ជី។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ១២៦៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលមានជនជាប់ចោទឈ្មោះ [redacted] មករា ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើត ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅមុនពេលចាប់ខ្លួនភូមិតាភុល សង្កាត់ ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] "រ" ម្តាយ ឈ្មោះ [redacted] "រ" កម្រិតវប្បធម៌ថ្នាក់ទី៧ ទោសពីមុនគ្មាន ជានីតិជន ឃុំខ្លួន តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១១៩៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ត្រូវបានចោទប្រកាន់ពីបទរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- លោក [redacted]រី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។
- បានឃើញ ដីកាដំណោះស្រាយលេខ ៦៧១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។
- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ២៩៥ ចុះថ្ងៃទី១[illegible] ខែមីនា ឆ្នាំ២០១៦ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

Scanned by CamScanner

## អង្គហេតុ ដែលត្រូវបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះ

កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ វេលាម៉ោង ៣និង៣០នាទីទៀបភ្លឺ ស្ថិតនៅភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប ដោយមានការសង្ស័យ កម្លាំងសមត្ថកិច្ចនគរបាលធ្វើការសាកសួរ ឈ្មោះ [redacted] មករា បានបណ្តើរម៉ូតូមួយគ្រឿងម៉ាក អ៊ែរប្លេក ពណ៌ឈាមជ្រូក ពាក់ស្លាកលេខស្វាយរៀង 1c 9305 និងបានឆែកឆេរលើខ្លួនប្រាណ ឃើញមានម្សៅក្រាមពណ៌សថ្លាចំនួន ១កញ្ចប់តូច។

## កិច្ចដំណើរការ នៃការពិនិត្យដេញដោល

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មករា ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។
- ក្រោយពីបានពិនិត្យភស្តុតាងសំណុំរឿងនេះ។

## សំអាងហេតុ

១. ឃើញថាជនជាប់ចោទឈ្មោះ [redacted] មករា បានឆ្លើយនៅមុខតុលាការថា សមត្ថកិច្ចឃាត់ខ្លួនខ្លួននៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ វេលាយប់ ខ្លួនបានអង្គុយលេងនៅម៉ាតត្រីកោណ។ នៅវេលាម៉ោង ២ភ្លឺ ខ្លួនជូនឈ្មោះ មួក ទៅផ្ទះ ដែលនៅជិតព្រលានយន្តហោះសៀមរាប។ ពេលត្រឡប់មកវិញម៉ូតូអស់សាំង ខ្លួនបានបណ្តើរដល់ចំណុចស្ពានការក៏មានម៉ូតូប៉ូលីសជិះចេញមក ហើយក៏បានសុំឆែកឆេរលើខ្លួន ក៏បានឃើញថ្នាំញៀន ដែលជ្រុះនៅលើដី។ ពេលនៅមន្ត្រីនគរបាលយុត្តិធម៌ខ្លួនបានប្រកែកថា មិនមែនរបស់ខ្លួនទេ។ តែតាមពិតជារបស់ខ្លួន ដែលខ្លួនទម្លាក់ចោលទៅលើដីខ្លាចសមត្ថកិច្ចឆែកឃើញ។ ខ្លួនសូមសារភាពថា ថ្នាំញៀន០១កញ្ចប់តូចនេះ ពិតជារបស់ខ្លួន។ ខ្លួនបានទិញពីឈ្មោះ សាល មួយកញ្ចប់តូចចំនួន ៣០.០០០ រៀល។ ខ្លួនទិញមកប្រើប្រាស់ទេ មិនបានលក់ដូរ ឬចែកចាយទេ។ សូមតុលាការ ជួយបន្ធូរបន្ថយទោស។

២. ឃើញថា តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះជនជាប់ចោទរូបនេះ។ ដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ និងសុំឲ្យតុលាការសម្រេចតាមច្បាប់។ តុលាការ ពិនិត្យ ពិចារណា និងសម្រេច តាមអង្គហេតុ និងអង្គច្បាប់។

៣. ឃើញថា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានលើកឡើងថា តាមសវនាការកន្លងមកនេះបានបញ្ជាក់ថា កូនក្តីខ្លួនមិនបានរក្សាទុកថ្នាំញៀនដោយខុសច្បាប់ឡើយ ដូចតាមការចោទប្រកាន់ឡើយ។ ប៉ុន្តែ កូនក្តីខ្លួនគ្រាន់តែទិញមួយកូនកញ្ចប់តូចចំនួន ៣០.០០០ រៀល តែប៉ុណ្ណោះដើម្បីយកមកប្រើប្រាស់ ហើយមិនទាន់បានយកមកប្រើប្រាស់ផង សមត្ថកិច្ចបានឆែកឃើញថ្នាំញៀនជាតិចតួចនេះ ហើយធ្វើការឃាត់ខ្លួនកូនក្តីខ្លួនតែម្តង។ ដូចនេះ ជាអង្គហេតុប្រើប្រាស់តែប៉ុណ្ណោះ។ ដូច្នេះ សូមឲ្យតុលាការ ឲ្យរួចខ្លួនពីបទចោទពីបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ព្រោះកូនក្តីខ្លួនបានប្រើប្រាស់តែប៉ុណ្ណោះ។ តុលាការ ពិនិត្យ ពិចារណា



Scanned by CamScanner

និងសម្រេចតាមអង្គហេតុ និងអង្គច្បាប់។

៤. ឃើញថា តាមសវនាការកន្លងមកនេះ បង្ហាញថា ជនជាប់ចោទ ពិតជាបានទិញថ្នាំបន្តិចបន្តួចនេះ សម្រាប់ប្រើប្រាស់តែប៉ុណ្ណោះ។ មិនមែនរក្សាទុកសម្រាប់ការចែកចាយ ឬជួញដូរឡើយ។ ដូច្នេះ ត្រូវឲ្យជនជាប់ចោទ បានរួចខ្លួនពីបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ០៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៥. ឃើញថា ជនជាប់ចោទឈ្មោះ [redacted] មករា នីតិជនមានស្មារតី គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ នូវអំពើរបស់ខ្លួន ដែលមានចេតនា ប្រព្រឹត្តនាំឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសង្គម។

៦. ឃើញថាវត្ថុចាប់យករួមមាន ម៉ូតូ១ គ្រឿង ម៉ាក air blade ពណ៌ខ្មៅលាយក្រហម ពាក់ស្លាកលេខស្វាយរៀង លេខតួលេខម៉ាស៊ីន lc 9305 RLHJF18018YG82350 (មានកូនសោរ) ចំនួន ១គ្រឿង ទូរស័ព្ទដៃម៉ាក sintel model m16 ទូរស័ព្ទដៃម៉ាក nokia model 6300 ពណ៌សូកូឡា ចំនួន ១គ្រឿង ទូរស័ព្ទដៃម៉ាក nokia 107 ពណ៌ខ្មៅចំនួន ១គ្រឿង ទូរស័ព្ទដៃម៉ាក nokia 105 ពណ៌ខៀវលាយខ្មៅសំបកពណ៌ ក្រហម ចំនួន ១គ្រឿង ដូចមានក្នុងដីកាបង្គាប់អោយរក្សាទុកវត្ថុដែលចាប់យកលេខ ៣៦៣ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តសៀមរាប ពុំមែនជាវត្ថុសំរាប់ប្រើជាមធ្យោបាយប្រព្រឹត្តបទល្មើសទេ។ ដូច្នេះ គប្បីប្រគល់អោយម្ចាស់ដើមវិញ។

<u>សន្និដ្ឋាន</u>៖ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលកំណត់ និងប្រកាសបានថាជនជាប់ចោទឈ្មោះ [redacted] មករាមានពិរុទ្ធភាព ពីបទ ប្រើប្រាស់ដោយ ខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌ០១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច

១. ឲ្យរួចខ្លួនពីបទចោទលើឈ្មោះ [redacted] មករា ពីបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ០៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ផ្តន្ទាទោសឈ្មោះ [redacted] មករា ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌ០១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned by CamScanner

៣. ប្រគល់វត្ថុតាងចាប់យករួមមាន ម៉ូតូ១ គ្រឿង ម៉ាក air blade ពណ៌ខ្មៅលាយក្រហម ពាក់ស្លាកលេខស្វាយរៀង លេខតួលេខម៉ាស៊ីន Ic 9305 RLHJF18018YG82350 (មានកូនសោរ) ចំនួន ១គ្រឿង ទូរសព្ទដៃម៉ាក sintel model m16 ទូរសព្ទដៃម៉ាក nokia model 6300 ពណ៌សូកូឡា ចំនួន ១គ្រឿង ទូរសព្ទដៃម៉ាក nokia 107 ពណ៌ខ្មៅចំនួន ១គ្រឿង ទូរសព្ទដៃម៉ាក nokia 105 ពណ៌ខៀវលាយខ្មៅ សំបកពណ៌ ក្រហម ចំនួន ១គ្រឿងដូចមានក្នុងពិការបញ្ជាប់អោយរក្សាទុក វត្ថុ ដែលចាប់យកលេខ៣៦៣ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តសៀមរាប អោយម្ចាស់ដើមវិញ។

សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ។ បើកសិទ្ធិអោយប្តឹងឧទ្ធរណ៍តាមនីតិវិធីនិងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

បានឃើញ
សៀមរាប ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦។
**ចៅក្រមជំនុំជម្រះ**
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។
សៀមរាប ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៦។
**ក្រឡាបញ្ជី**
[redacted]

Scanned by CamScanner